ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣៥ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការតែងតាំងសមាសភាពក្រុមការងារថ្នាក់ជាតិ ដើម្បីអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈ នៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្ដាប្រទេសពាក់ព័ន្ធ ស្ដីពីការលុបបំបាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះដោយសារការជួញដូរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៥ / ០០២ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខានៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩២ និងបានផ្ដល់សច្ចាប័ននៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ១៩៩២
- បានឃើញអនុសញ្ញាស្ដីពីសិទ្ធិកុមារ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខានៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩២ និងបានផ្ដល់សច្ចាប័ននៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ១៩៩២

www.pheakdeylaw.com

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣២ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការអន្តរជាតិខាងការងារលេខ ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៦ / ០០៤ ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- បានឃើញសេចក្តីសម្រេចលេខ ១៣ សសរ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិដើម្បីអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសពាក់ព័ន្ធ ស្តីពីការលុបបំបាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះដោយសារការជួញដូរ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី /

# ស ម្រេ ច

**ប្រការ ១.-**

ត្រូវបានតែងតាំងសមាសភាពក្រុមការងារថ្នាក់ជាតិ ដើម្បីអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសពាក់ព័ន្ធ ស្តីពីការលុបបំបាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះដោយសារការជួញដូរ (**ក.អ.ល.ជ**) ដូចតទៅ :

| | | | |
|---|---|---|---|
| ១- | លោកជំទាវ **យូ អយ** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ប្រធាន |
| ២- | ឯកឧត្តម **នូ តឿង** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- | ឯកឧត្តម **នឹម ចំន្ទតារា** | អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៤- | ឯកឧត្តម **ម៉ុល ម៉េងឃួរ** | អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៥- | ឯកឧត្តម **អ៊ិត រ៉ាឌី** | អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៦- | ឯកឧត្តម **ខឹម ទិសិដ្ឋ** | សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធាននាយកដ្ឋានអប់រំ វប្បធម៌ សង្គមកិច្ច ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

www.pheakdeylaw.com

| | | | |
|---|---|---|---|
| ៧- | ឯកឧត្តម **លី អៀមឡាក់** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- | លោក **ឌូច សាម៉ុន** | អគ្គនាយករងបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៩- | លោកស្រី **ញឹម ច័ន្ទចំនួតគន** | អគ្គាធិការរង ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១០- | លោក **ហោ សារុន** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ និងជាប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ក្រសួងទេសចរណ៍ | សមាជិក |
| ១១- | លោកស្រី **ហេង ស៊ីថុន** | អគ្គនាយករងអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី | សមាជិកអចិន្ត្រៃយ៍ |
| ១២- | លោក **យូ ឆ័រសិទ្ធ** | អគ្គលេខាធិការរង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | សមាជិក |
| ១៣- | លោកស្រី **ជា ផល្លីន** | អគ្គនាយករងវិទ្យុជាតិកម្ពុជា ក្រសួងព័ត៌មាន | សមាជិក |
| ១៤- | លោកឧត្តមសេនីយ៍ត្រី **អ៊ុង សារ៉ាន់** | នាយសេនាធិការរង កងរាជអាវុធហត្ថ ក្រសួងការពារជាតិ | សមាជិក |
| ១៥- | លោកស្រីឧត្តមសេនីយ៍ត្រី **អ៊ិន សុគន្ធា** | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ | សមាជិក |
| ១៦- | លោក **ទេព ហៀង** | ប្រធាននាយកដ្ឋានការងារកុមារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៧- | លោក **គីម សុវណ្ណា** | អនុប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៨- | លោកស្រី **ចំនួ មារ៉ាន់ទង្គី** | អគ្គលេខាធិការរង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | សមាជិក |

**ប្រការ ២.-**

សមាជិក សមាជិកា នៃ **ក.អ.ល.ជ** មានភារកិច្ចអនុវត្តការងារទៅតាមការតម្រង់ទិសដៅនៃសេចក្តីសម្រេចលេខ ១៣ សសរ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការបង្កើតក្រុមការងារ ថ្នាក់ជាតិដើម្បីអនុវត្តកិច្ចព្រមព្រៀងអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសពាក់ព័ន្ធ ស្តីពីការលុបបំបាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះដោយសារការជួញដូរ ។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

www.pheakdeylaw.com

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៤*
- *រាជកិច្ច* ✓
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com